# ព្រះរាជក្រឹត្យ

នស/រកត/០៥២០/៥៨១

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សារៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១:**

ត្រូវបានបង្កើត **ក្រុមប្រឹក្សារៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង** [illegible]សរសេរជាអក្សរកាត់ថា "**ក.ផ.ស.**"។ **ក.ផ.ស.** មានភារកិច្ចដឹកនាំ និងសម្របសម្រួលការរៀបចំ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះមហាក្សត្រ

ផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

គ.ជ.ស. មានសមាសភាព ដូចតទៅ÷

| | | |
|---|---|---|
| ១- នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ១៨- រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | | សមាជិក |
| ១៩- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ២០- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១ (មួយ) រូប | សមាជិក |
| ២១- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ (មួយ) រូប | សមាជិក |
| ២២- រដ្ឋលេខាធិការក្រសួងការពារជាតិ | ១ (មួយ) រូប | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ (មួយ) រូប សមាជិក

២៤- ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ១ (មួយ) រូប សមាជិក

២៥- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១ (មួយ) រូប សមាជិក

២៦- អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក។

សមាសភាពជាក់ស្តែងនៃ គ.ជ.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

គ.ជ.ស. មានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង សរសេរជាអក្សរកាត់ថា "គ.ស.ជ." ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធជាសមាជិក ជាសេនាធិការ ក្នុងការសម្របសម្រួលអន្តរស្ថាប័នសម្រាប់ធានាកិច្ចដំណើរការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គ.ស.ជ. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤.-**

គ.ជ.ស. មានគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង រៀបចំគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង សរសេរជាអក្សរកាត់ថា "គ.ម.ជ." ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធជាសមាជិក ជាយន្តការបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន ទទួលបន្ទុករៀបចំគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គ.ម.ជ. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥.-**

គ.ជ.ស. អាចបង្កើតគណៈកម្មាធិការ គណៈកម្មការ ឬក្រុមការងារមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការ, គណៈកម្មការ ឬក្រុមការងារ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ជំពូកទី៣**

**តួនាទី និងភារកិច្ចរបស់ គ.ជ.ស.**

**មាត្រា៦.-**

គ.ជ.ស. មានភារកិច្ចដូចតទៅ÷




- ដឹកនាំ និងគាំទ្រកិច្ចការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- ផ្តល់អនុសាសន៍អំពីគោលការណ៍, គោលដៅ, ក្របខណ្ឌ និង កិច្ចការសំខាន់ៗ សម្រាប់រៀបចំផែនការមេ
- ដឹកនាំសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមធំៗ ក្នុងការរៀបចំផែនការមេ

- ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការរៀបចំផែនការមេ
- រៀបចំសេចក្ដីព្រាងផែនការមេ និងឯកសារចាំបាច់ដែលមានការពាក់ព័ន្ធ ជូនគណៈរដ្ឋមន្ត្រី ពិនិត្យនិងអនុម័ត។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ ក.ជ.ស.

**មាត្រា៧.-**

ក្នុងករណីអវត្តមាន ឬមានធុរៈ អនុប្រធាន និងសមាជិក **ក.ជ.ស.** ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ប្រធានប្រគល់សិទ្ធិជូនអនុប្រធានមួយរូប ដើម្បីដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិពីប្រធាន។

ក.ជ.ស. ប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី សម្រាប់ដំណើរការការងារ។

**មាត្រា៨.-**

ក.ជ.ស. អាចអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និងបំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។

ក.ជ.ស. អាចអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍, តំណាងវិស័យឯកជន, តំណាងសង្គមស៊ីវិល, ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំក្នុងឋានៈជាសមាជិក, អ្នកសង្កេតការណ៍ ឬអ្នកផ្ដល់យោបល់ តាមការចាំបាច់។

**មាត្រា៩.-**

ទីស្ដីការគណៈរដ្ឋមន្ត្រី បំពេញមុខងារជាសេនាធិការរដ្ឋបាល សម្រាប់ការរៀបចំកិច្ចប្រជុំរបស់ **ក.ជ.ស.**។ **គ.ស.ជ.** ទទួលបន្ទុកសម្របសម្រួលអន្តរស្ថាប័នផ្នែកបច្ចេកទេស និងខ្លឹមសារសម្រាប់កិច្ចប្រជុំរបស់ **ក.ជ.ស.**។

**មាត្រា១០.-**

គណៈកម្មាធិការ គណៈកម្មការ ឬក្រុមការងារនានាស្ថិតក្រោម **ក.ជ.ស.** ត្រូវរាយការណ៍ការងារជូន ក.ជ.ស. តាមរយៈ គ.ស.ជ.។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា១១.-**

ក.ជ.ស. ប្រើប្រាស់ថវិកាជាតិរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីសម្រាប់កិច្ចដំណើរការ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

គណៈកម្មាធិការ គណៈកម្មការ ឬ ក្រុមការងារនានា ក្រោមឱវាទ **គ.ផ.ស.** រួមទាំង **គ.ស.ផ.** និង **គ.ម.ជ.** ប្រើប្រាស់ប្រភពធនធានថវិកានៅក្នុងក្របខ័ណ្ឌថវិការបស់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចដឹកនាំគណៈកម្មាធិការ គណៈកម្មការ ឬ ក្រុមការងារនីមួយៗ។

**គ.ផ.ស.** និងគណៈកម្មាធិការ គណៈកម្មការ ឬ ក្រុមការងារ ក្រោមឱវាទ **គ.ផ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗស្របច្បាប់ សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

៣៧.២០០៥.៥៩៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**